# ការវាយតម្លៃឆាប់រហ័សពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច មកលើក្រុមគ្រួសារកម្ពុជា និងពលករងាយរងគ្រោះ[1]

## សេចក្ដីផ្ដើម និងវិធីសាស្ត្រ

ចាប់តាំងពីវិបត្តិហិរញ្ញវត្ថុសាកល បានលេចរូបរាងច្បាស់នៅខែកញ្ញា ២០០៨ មក វាបានប៉ះពាល់ខ្លាំងបំផុតដល់វិស័យជំរុញកំណើនចំបងៗរបស់កម្ពុជា ពោលគឺ វិស័យកាត់ដេរ ទេសចរណ៍ និងសេវាកម្ម និងសំណង់ ។ ការរួមចុះក្នុងវិស័យទាំងនេះ បានធ្វើឲ្យការងាររាប់ម៉ឺនត្រូវបាត់បង់ ប្រាក់សន្សំនិងប្រាក់ផ្ញើទៅផ្ទះបានធ្លាក់ចុះ ហើយប្រជាជនក្រីក្រនិងជនងាយរងគ្រោះជាទូទៅត្រូវជួបនឹងហានិភ័យ ។ សំពាធបានកើនឡើងដោយជៀសមិនផុតលើសេដ្ឋកិច្ចជនបទ (ជាពិសេស កសិកម្ម) ដែលកំពុងតឹងតែងស្រាប់ហើយដោយសារ កង្វះវិនិយោគ ភាពអន់ថយ និងការពឹងផ្អែកខ្លាំងលើលក្ខខណ្ឌធម្មជាតិ ។ សេដ្ឋកិច្ចជនបទដែលមិនសូវរស់រវើក និងមានមូលដ្ឋានតូចចង្អៀត បានធ្វើឲ្យប្រជាជនជនបទមួយភាគធំ មានមធ្យោបាយនិងជំរើសការងារតិចតួច ដើម្បីទប់ទល់នឹងការប៉ះទង្គិចលើប្រាក់ចំណូល និងចំណាយប្រើប្រាស់ ដោយសារវិបត្តិសេដ្ឋកិច្ចសាកល ។ កម្ពុជាមិនបានគេចផុតពីវិបត្តិសេដ្ឋកិច្ចសាកលទេ ទោះបីរដ្ឋាភិបាល បានប្រើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចល្អត្រឹមត្រូវក៏ដោយ ។ យុទ្ធសាស្ត្រដោះស្រាយរបស់ជនក្រីក្រ និងងាយរងគ្រោះ នៅមុន និងនៅក្រោយពេលមានវិបត្តិ វាមានប្រសិទ្ធភាពតិចតួច បើធៀបនឹងផលប៉ះពាល់នានា ។ ចំលើយតបខាងគោលនយោបាយជាក់លាក់ផ្សេងៗរបស់កម្ពុជា ទៅនឹងវិបត្តិហិរញ្ញវត្ថុសាកល ទំនងមានដំណើរការយឺត ហើយការវិវត្តមិនទៀងទាត់នៃវិស័យជំរុញកំណើនរបស់កម្ពុជា នឹងបន្តប៉ះពាល់ដល់ជីវភាពប្រជាជននៅថ្ងៃខាងមុខទៀត ។

ការវាយតម្លៃនេះ ព្យាយាមពិនិត្យពី៖ (១) លក្ខណៈដើមហេតុ និងទំហំបំលាស់ប្តូរក្នុងស្ថានភាពរបស់បុគ្គល និងគ្រួសារនៅពេលសេដ្ឋកិច្ចកម្ពុជាកំពុងចាប់ផ្តើមរើបចេញពីវិបត្តិនេះ (២) ការប្រែប្រួលក្នុងយុទ្ធសាស្ត្រដោះទ័ល របស់ក្រុមជនងាយរងគ្រោះផ្សេងៗ និង (៣) ប្រសិទ្ធភាព និងការគ្របដណ្តប់នៃប្រព័ន្ធសុវត្ថិភាពសង្គម ។

ការវាយតម្លៃនេះជាជុំទីបួន និងជាជុំចុងក្រោយ នៃការសិក្សាមួយអនុវត្តដោយ CDRI ក្នុងខែកុម្ភៈ ២០១០ ក្រោមហិរញ្ញប្បទានពីធនាគារពិភពលោក ។ ការវាយតម្លៃបីជុំមុន ធ្វើឡើងក្នុងខែឧសភា សីហា និង វិច្ឆិកា ២០០៩ ដែលជាការសិក្សាជាក្រុមមានរយៈពេល ៣ខែ នៅខេត្តសៀមរាប បាត់ដំបង ព្រៃវែង កំពត កណ្តាល កំពង់ស្ពឺ និងក្រុងភ្នំពេញ ។ ការវាយតម្លៃជុំទីបួននេះជាការសិក្សាបែបគុណភាព ដែលរួមមាន ១៧ ការពិភាក្សាតាមក្រុមស្នូល (FGDs) ជាមួយនឹងគ្រួសារនៅជនបទ ក្នុង ៦ ភូមិខុសៗគ្នា និង ១១ ក្រុមពលករងាយរងគ្រោះក្នុង ៣ វិស័យជំរុញកំណើន គឺវិស័យកាត់ដេរ ទេសចរណ៍និងសេវាកម្ម និងសំណង់ ។ ដោយសារទំហំគំរូតាងតូច ដូច្នេះលទ្ធផលរកឃើញ និងការបកស្រាយ មិនអាចយកទៅប្រើសំរាប់ពលករក្រីក្រ និងងាយរងគ្រោះទាំងអស់នៅកម្ពុជាទេ ប៉ុន្តែអាចជួយបំភ្លឺ និងផ្តល់គំនិតមួយចំនួនពីបែបបទដែលការប៉ះទង្គិចលើសេដ្ឋកិច្ចនាពេលថ្មីៗ បានប៉ះពាល់ដល់ពលករងាយរងគ្រោះ និងគ្រួសារក្រីក្រនានា ។

## លទ្ធផលរកឃើញសំខាន់ៗ

### បំលាស់ប្តូរចំបងៗក្នុងជីវភាពរស់នៅ និងផលប៉ះពាល់ផ្សេងៗ

FGDs រាយការណ៍ពីបំលាស់ប្តូរជាវិជ្ជមាន និងអវិជ្ជមាន ក្នុងរយៈពេល ៣ខែកន្លងទៅ ដែលទំនងកើតចេញពីប្រភពចំបងៗ ៣គឺ៖ (១) ការវិវត្តសេដ្ឋកិច្ចក្នុងពេលថ្មីៗ និងចំណាយរស់នៅខ្ពស់ (២) លក្ខខណ្ឌធម្មជាតិ និង (៣) បំលាស់ប្តូរជីវភាពរស់នៅតាមរដូវ ។

ការរើបឡើងនៃវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ផុសឡើងស្របគ្នានឹង ការរើបឡើងវិញនៃសេដ្ឋកិច្ចសាកល ។ FGDs បានរាយការណ៍ពីបំលាស់ប្តូរជាវិជ្ជមាននៃ ចំនួនការងារសំរាប់កម្មករកាត់ដេរ ក្នុងរោងចក្រចំនួន ៣ ដែលយើងបានចុះពិនិត្យ លើកលែងកម្មករធ្វើការក្នុងរោងចក្រកាត់ដេរ មិថុនា[2] ដែលបានប្រាប់ថា ពុំមានការងារថែមម៉ោងសំរាប់ធ្វើទេ ។[3] កំណើនភ្ញៀវទេសចរមកដល់ខេត្តសៀមរាប បង្ហាញពីកំណើនចំនួនការងារអាចរកបាន និងចំណូលសំរាប់ អ្នកធ្វើការក្នុងវិស័យសេវាកម្ម (លើកលែង បុគ្គលិកភោជនីយដ្ឋាននៅទីក្រុងភ្នំពេញ) អ្នករត់ទុកទុក និងអ្នកលក់ដូរតូចតាច ។[4] ការងារសំរាប់កម្មករសំណង់មានជំនាញបានកើនឡើងបន្តិចដែរ ដោយសារកំណើនគម្រោងសាងសង់តូចៗ និងសកម្មភាពនៅតាមការដ្ឋានសំណង់ចំបងៗមួយចំនួន ។ ប៉ុន្តែស្ថានភាពកម្មករគ្មានជំនាញវិញ ពុំមានរបាយការណ៍ថាបានល្អប្រសើរឡើងទេ ហើយមានខ្លះថែមទាំងប្រាប់ថាវាកាន់តែយ៉ាប់យ៉ឺនថែមទៀត ។ គ្រប់ក្រុមអ្នកឆ្លើយសម្ភាសន៍ និង

---

១ អត្ថបទនេះរៀបរៀងដោយ កឹម សុធន ជាអ្នកស្រាវជ្រាវ ចេង វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធី និង ឈឹម ឈន់ ជាជំនួយការស្រាវជ្រាវនៃកម្មវិធី ភាពក្រីក្រ កសិកម្ម និងការអភិវឌ្ឍន៍ជនបទ របស់វិទ្យាស្ថាន CDRI ។ អ្នកនិពន្ធ សូមសំដែងការអរគុណដល់លោកស្រី ខៀវ ភិរម្យ កញ្ញា ផាន់ ដាលីស និង លោក យៀង សុធី សំរាប់ការជួយចូលរួមចំណែកក្នុងការសិក្សានេះ ។

២ មានទីតាំងនៅក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៣ ការនាំចេញសំលៀកបំពាក់សរុប នៅខែវិច្ឆិកា ២០០៩ មានជិតដល់ ២៥០លានដុល្លារ ធៀបនឹង ៦០លានដុល្លារ នៅខែកញ្ញា ២០០៩ (ស្ថិតិសេដ្ឋកិច្ច និងរូបិយវត្ថុ នៃ NBC) ។ ការរួមចុះសេដ្ឋកិច្ចកំពុងកើតមាននៅសហរដ្ឋអាមេរិក បានប៉ះពាល់ខ្លាំងណាស់ ដល់វិស័យកាត់ដេរកម្ពុជា (CDRI ខែវិច្ឆិកា ២០០៩) ។

៤ ចំនួនភ្ញៀវមកដល់កម្ពុជា នៅខែធ្នូ ២០០៩ មានប្រហែល ២០០.០០០នាក់ (CDRI ខែធ្នូ ២០០៩) ។

គ្រួសាររបស់ពួកគេ បន្តទ្រាំទ្រនឹងចំណាយរស់នៅខ្ពស់ និងការឡើងថ្លៃម្ហូបអាហារ ហើយបញ្ហានេះប៉ះពាល់ខ្លាំងលើ អ្នកធាក់ស៊ីក្លូ និងកម្មករសំណង់គ្មានជំនាញ ។

ទិន្នផលស្រូវខ្ពស់ គេទទួលបាននៅភូមិកំពង់ត្នោត បាបោង និងក្រសាំង ដោយសារមានភ្លៀងធ្លាក់គ្រប់គ្រាន់ ។[5] ផលស្រូវល្អបានបង្កើនប្រាក់ចំណូលពីកសិកម្ម ដែលជួយឲ្យកសិករអាចសងបំណុលគេខ្លះ និងបង្កើនចំណាយប្រើប្រាស់របស់ខ្លួន ។ នៅភូមិទាំងបីនេះ ការសិក្សារកឃើញដូចគ្នាថា មូលធនកើតចេញពីប្រាក់ចំណូលបានពីកសិកម្ម ជួយឲ្យកសិករធ្វើពិពិធកម្មសកម្មភាពចិញ្ចឹមជីវិតរបស់ខ្លួន ។ ប៉ុន្តែមិនមែនគ្រប់ភូមិសុទ្ធតែមានសំណាងដូចគ្នាទេ ។ លក្ខខណ្ឌធម្មជាតិមិនអំណោយផល ដូចជាភ្លៀងធ្លាក់ច្រើនពេកនៅរដូវច្រូតកាត់ និងការកើតសត្វចង្រៃបំផ្លិចបំផ្លាញ ធ្វើឲ្យផលស្រូវខូចខាតធ្ងន់ធ្ងរ ។ នៅភូមិត្រពាំងប្រីយ៍[6] ការខូចខាតដំណាំស្រូវដោយសារកណ្តុរ មាន ៣០% ធៀបនឹងទិន្នផលក្នុងឆ្នាំ២០០៨ ។ ទិន្នផលស្រូវ និងចំណូលពីស្រែចំការទាប នាំឲ្យគ្រួសារកសិករជួបការលំបាកកាន់តែខ្លាំងជៀសមិនផុត និងទំនងជាត្រូវខ្ចីបុលគេយ៉ាងច្រើន ។ ការងារក្រៅកសិដ្ឋាន និងប្រាក់ផ្ញើមកផ្ទះពីសមាជិកគ្រួសារធ្វើការក្នុងវិស័យកាត់ដេរ ឬសំណង់ ឬក្នុងប្រទេសថៃ គឺជាប្រភពចំណូលមួយទៀតសំរាប់គ្រួសារ ។

> *"អ្នកមានកូនប្រុស ឬកូនស្រី ឬសមាជិកគ្រួសារធ្វើការនៅទីក្រុង មានសំណាងជាងពួកខ្ញុំឆ្ងាយ ។ យ៉ាងហោចណាស់ ពួកគេមានអ្នកផ្ញើលុយមកឲ្យទិញម្ហូបអាហារ និងចាយវាយផ្សេងៗក្នុងគ្រួសារ ដូច្នេះមិនសូវភ័យថាអត់អីហូបនោះទេ ទោះបីធ្វើស្រូវមិនបានគ្រប់គ្រាន់ ។" (ស្ត្រីៗក្នុង FGD នៅភូមិត្រពាំងប្រីយ៍)*

ប្រជាជនក្នុងភូមិសិក្សានានា ភាគច្រើនធ្វើការងារក្រៅកសិដ្ឋានតាមរដូវនៅមូលដ្ឋាន នៅក្នុង ឬនៅក្បែរភូមិរបស់ខ្លួន បន្ទាប់ពីច្រូតកាត់រួច ។ ការងារទាំងនេះភាគច្រើនជារបៀបប្រពៃណីក្នុងភូមិ និងមិនសូវប៉ះពាល់ខ្លាំងពីវិបត្តិសេដ្ឋកិច្ចទេ ។ តួយ៉ាងប្រជាជននៅភូមិកំពង់ត្នោត អាចនេសាទត្រីសមុទ្របានច្រើន ដោយសារមិនមានខ្យល់ខ្លាំង ហើយខ្លះទៀតធ្វើការក្នុងផលិតកម្មអំបិលនៅរដូវប្រាំង (ខែវិច្ឆិកា ២០០៩-កុម្ភៈ ២០១០)។ នៅភូមិបាបោង និងត្រពាំងប្រីយ៍ ប្រជាជនលក់ពលកម្មលីបាវស្រូវ អង្ករ លើកដី និងក្នុងផលិតកម្មស្ករត្នោតជាដើម ។

រៀងរាល់រដូវប្រាំង មានចលនាផ្លាស់ទីយ៉ាងធំមួយនៃកម្មករសំណង់មាន និងគ្មានជំនាញ ពីជនបទ ទៅទីក្រុង ហើយខ្លះទៀតធ្វើចំណាកស្រុកទៅធ្វើការតាមកសិដ្ឋាននៅប្រទេសថៃ ។ មានលក្ខខណ្ឌ២យ៉ាងដែលទំនងប៉ះពាល់លើក្រុមចំណាកស្រុក។ ទីមួយ កាលណាមានមនុស្សកាន់តែច្រើនឡើងមកទីក្រុងរកការងារធ្វើ ការប្រកួតប្រជែងផ្នែកការងារក៏កើនឡើងដែរ ជាពិសេសក្នុងចំណោមអ្នកធាក់ស៊ីក្លូ និងកម្មករសំណង់មាន និងគ្មានជំនាញ ។ ទីពីរ កត្តានេះបានបន្ទាប ប្រាក់កម្រៃដែលថយចុះស្រាប់ហើយដោយសារវិបត្តិសេដ្ឋកិច្ច។ទីពីរពលករចំណាកស្រុកនៅភូមិអណ្តូងត្រាច (ក្នុងឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង) និងភូមិក្រសាំង និយាយថា កំណើនការប្រើប្រាស់គ្រឿងចក្រកសិកម្មនៅតាមកសិដ្ឋាននៅប្រទេសថៃ បានគំរាមកំហែងដល់ការងាររបស់ខ្លួន ។ វិបត្តិសេដ្ឋកិច្ចសាកល ក៏បានកាត់បន្ថយតម្រូវការ និងថ្លៃផលិតផលកសិកម្មផងដែរ ។ បញ្ហានេះបណ្តាលឲ្យកសិករថៃបោះបង់ដំណាំរបស់ខ្លួន ហើយកាត់បន្ថយតម្រូវការជួលពលករកម្ពុជាមកធ្វើការក្នុងកសិដ្ឋាន ។ ព្រឹត្តិការណ៍ទាំងនេះ ប៉ះពាល់ទាំងពលករចំណាកស្រុក និងគ្រួសាររបស់ពួកគេ ។

### បំលាស់ប្តូរការងារ ចំណូល និងប្រាក់សន្សំ

*ការងារអាចរកបាន*

ក្នុងអំឡុងពេលសិក្សាស្រាវជ្រាវ ការរើបសេដ្ឋកិច្ចទោះបីមិនទាន់ខ្លាំងក្តី ក៏បានជះឥទ្ធិពលដោយផ្ទាល់កាន់តែច្រើនទៅលើវិស័យកាត់ដេរ ទេសចរណ៍ និងផ្នែកខ្លះនៃវិស័យសំណង់ ។ ពលករក្នុងវិស័យសេវាកម្ម និងកាត់ដេរ បញ្ជាក់ថា ស្ថានភាពការងារដែលអាចរកបាន សឹងតែគ្មានអ្វីប្រែប្រួល បើធៀបនឹងការសិក្សានៅជុំមុនៗ។ ការដ្ឋានសាងសង់ចំបងៗមួយចំនួននៅក្រុងភ្នំពេញ ដែលចាប់ដំណើរការឡើងវិញ បានជួយដល់កម្មករសំណង់មានជំនាញ ។ ផ្ទុយទៅវិញ តម្រូវការទាបនូវកម្មករសំណង់គ្មានជំនាញ បានបន្តដដែលនៅខែកុម្ភៈ ស្របពេលចំនួនកម្មករបានកើនឡើង ។ កម្មករភាគច្រើន រកការងារធ្វើបានតិចជាង ១០ថ្ងៃ/ខែ ។ ចំនួនថ្ងៃធ្វើការសំរាប់អ្នកធាក់ស៊ីក្លូ និងកម្មករភោជនីយដ្ឋាននៅក្រុងភ្នំពេញ គ្មានប្រែប្រួលទេ ប៉ុន្តែពួកគេប្រាប់ថា អតិថិជនបានថយចុះចំនួន ។

*ប្រាក់កំរៃ*

ធៀបនឹងការសិក្សានៅជុំទី៣ អ្នកធាក់ស៊ីក្លូ និងកម្មករភោជនីយដ្ឋាន រកចំណូលប្រចាំថ្ងៃបានដូចមុន ប្រសិនបើពួកគេធ្វើការលើសមុន ២ម៉ោង រាល់ថ្ងៃ ។ កម្មករសំណង់គ្មានជំនាញទទួលបានប្រាក់កំរៃតិចជាងមុន ត្រឹម ១៣.០០០រៀល/ថ្ងៃ ឬ ១០% ទាបជាងការវាយតម្លៃកាលពី ៣ខែមុន ។ ស្រដៀងគ្នាដែរ ពលករចំណាកស្រុកពីភូមិអណ្តូងត្រាច និងភូមិក្រសាំង ដែលទៅធ្វើការតាមកសិដ្ឋាននៅប្រទេសថៃ ទទួលបានកំរៃ ៤០% តិចជាងការវាយតម្លៃនៅជុំទី៣ ។ អ្នករត់ទុកទុក និងអ្នកលក់ដូរតូចតាចនៅខេត្តសៀមរាប បានឆ្លើយសម្ភាសន៍ប្រាប់ថា រកចំណូលបាន ៥ដុល្លារ និង ៣ដុល្លារ រៀងគ្នា ដោយសារកំណើនភ្ញៀវទេសចរ ។ កម្មករភោជនីយដ្ឋាន និងសណ្ឋាគារនៅសៀមរាប ប្រាប់ថា ពួកគេទទួលបានបៀវត្សរ៍ និងប្រាក់ទឹកតែច្រើនជាងមុនបន្តិច ។

*ប្រាក់សន្សំ និងប្រាក់ផ្ញើមកផ្ទះ*

ការរើបសេដ្ឋកិច្ចនាពេលថ្មីៗ ទំនងជះឥទ្ធិពលខ្លាំងទៅលើការងារដែលអាចរកបាន និងចំណូលសំរាប់កម្មករកាត់ដេរ និងកម្មករខាងសេវាកម្មនិងទេសចរណ៍ ។ កម្មករកាត់ដេរ អាចផ្ញើប្រាក់ពី ៣០-៦០ដុល្លារ ទៅឲ្យក្រុមគ្រួសារជារៀងរាល់ខែ ។ ប៉ុន្តែប្រាក់សន្សំ និងប្រាក់ផ្ញើទៅផ្ទះ បន្តធ្លាក់ចុះ សំរាប់អ្នកធាក់ស៊ីក្លូ កម្មករសំណង់

---

៥ ភូមិកំពង់ត្នោត ស្ថិតក្នុង ឃុំកូនសត្វ ស្រុកកំពត ខេត្តកំពត ។ ភូមិបាបោង ស្ថិតក្នុង ឃុំបាបោង ស្រុកពាមរ ខេត្តព្រៃវែង ។ ភូមិក្រសាំង ស្ថិតក្នុង ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង ។

៦ ភូមិត្រពាំងប្រីយ៍ ស្ថិតក្នុង ឃុំក្សេមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

គ្មានជំនាញ និងពលករចំណាកស្រុក ព្រោះពួកគេរកការងារធ្វើបានតិចជាងមុន និងទទួលបានកំរៃទាបជាងមុន ។ FGDs ក្នុងភូមិចំនួន ៦ បង្ហាញពីកំណើនចំណូលតាមរដូវសម្រាប់គ្រួសារជាទូទៅ បើធៀបនឹងការសិក្សានៅជុំទី៣ ដោយសារមានការងារក្រៅកសិដ្ឋានធ្វើច្រើន ។ ប៉ុន្តែការប្រែប្រួលនេះមិនសូវធំដុំទេ បើធៀបនឹងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន ។ តួយ៉ាងអ្នកភូមិកំពង់ត្នោតរកចំណូលបាន ១៤០.០០០រៀល/ខែ ពីការងារក្នុងផលិតកម្មអំបិលហើយអ្នកភូមិបាបោងរកបានពី២០.០០០-៣០.០០០រៀល ពីការធ្វើនំលក់ ដែលការងារទាំងនេះ មិនមានធ្វើទេកាលពីការសិក្សានៅជុំទី៣ ។ ថ្លៃអាហារខ្ពស់ និងចំណាយរស់នៅខ្ពស់ បណ្ដាលជាចំបងពីការធ្លាក់ចុះប្រាក់សន្សំ និងប្រាក់ផ្ញើមកផ្ទះ ។

## ការបែងចែកកំលាំងពលកម្មក្នុងក្រុមគ្រួសារ

ការងារអាចរកបានតាមរដូវកាល និងការរើបសេដ្ឋកិច្ចនាពេលថ្មីៗហាក់ដូចបានកំណត់នូវការបែងចែកកំលាំងពលកម្មក្នុងគ្រួសារ ។ ដូចក្នុងការសិក្សាស្រាវជ្រាវជុំមុនដែរ សមាជិកពេញវ័យក្នុងគ្រួសារជាពិសេសឪពុកម្ដាយ ធ្វើទាំងការងារនៅកសិដ្ឋាន និងការងារក្រៅកសិដ្ឋានយកប្រាក់កម្រៃ ។ ឱកាសការងារនៅតាមជនបទទាំងនេះប្រែប្រួលតាមស្ថានភាពសេដ្ឋកិច្ច និងរដូវកាល ។ ការសិក្សាស្រាវជ្រាវជុំនេះ មិនបានរកឃើញសញ្ញាអ្វីថា ការធ្លាក់ចុះសេដ្ឋកិច្ច ធ្វើឲ្យប្រជាជននៅជនបទធ្វើការលំបាកជាងពីមុនទេ ប៉ុន្តែ FGDs បង្ហាញថា ការស្វែងរកការងារតឹងតែងជាងមុន ។ នៅតាមភូមិស្ត្រីនៅតែបន្តធ្វើការងារក្នុងផ្ទះភាគច្រើន ដោយមានជំនួយខ្លះៗពីកុមារជាកូនៗរបស់ខ្លួន ដូចជា ការបេះប្រមូលផលពីធនធានទ្រព្យរួមជាដើម (ឧ. របស់ហូបរកពីវាលស្រែ) ។

នៅភូមិកំពង់ត្នោតមានករណីដែលឪពុកម្ដាយបានបញ្ឈប់ការសិក្សាកូនៗ ដើម្បីឲ្យជួយការងារផ្ទះ ឬឲ្យធ្វើការក្នុងផលិតកម្មអំបិល (ក្រសួងការងារបានឲ្យដឹងថា ការងារនេះស្ថិតក្នុងចំណោមទំរង់អាក្រក់ៗបំផុតនៃពលកម្មកុមារ) ។ យុវជនឬកុមារស្ថិតក្នុងវ័យកំពុងលូតលាស់ធំ ភាគច្រើនធ្វើការងារប្រភេទខ្លះដើម្បីរកកំរៃក្នុងរោងចក្រកាត់ដេរ ការដ្ឋានសំណង់ កសិដ្ឋានក្នុងប្រទេសថៃ ឬផ្នែកនេសាទ ។ ពួកគេស្ថិតក្នុងចំណោមអ្នករកចំណូលសំខាន់ៗសំរាប់គ្រួសារ ។ ម៉ោងធ្វើការផ្អែកលើការងារអាចរកបានដែលប្រែប្រួលទៅតាមស្ថានភាពសេដ្ឋកិច្ច ។ កម្មករសំណង់មាន និងគ្មានជំនាញ អះអាងថាបានខំស្វែងរកការងារធ្វើណាស់ រីឯអ្នកធាក់ស៊ីក្លូទទួលធ្វើការងារផ្សេងទៀតដូចជា លីសែងទំនិញជាដើម ។

## យុទ្ធសាស្ត្រដោះស្រាយ

សកម្មភាពនានាដើម្បីទប់ទល់នឹងការប៉ះទង្គិចពីលក្ខខណ្ឌធម្មជាតិមិនអំណោយផល ឬវិបត្តិសេដ្ឋកិច្ច គឺប្រហែលគ្នានឹងការរកឃើញក្នុងការសិក្សាជុំមុនដែរ ប៉ុន្តែមានលំនាំខុសគ្នាបន្តិច ។

### *បម្រែបម្រួលលំនាំចំណាយ*

ការកាត់បន្ថយចំណាយប្រើប្រាស់មិនមែនអាហារ នៅតែជាយុទ្ធសាស្ត្រសំខាន់សម្រាប់ទប់ទល់នឹង ទំនិញឡើងថ្លៃ ចំណាយរស់នៅខ្ពស់ និងការប៉ះទង្គិចផ្សេងៗទៀត ។ ធៀបនឹងការសិក្សានៅជុំទី៣ ក្នុងពេលចាប់ផ្តើមឆ្នាំសិក្សាថ្មី យើងឃើញមានបម្រែបម្រួលក្នុងចំណាយប្រើប្រាស់មិនមែនអាហារ ដូចជា ចំណាយព្យាបាលសុខភាពបន្ទាន់ និងចំណាយលើការសិក្សារបស់កូនៗ ជាដើម ។

ការសិក្សាជុំនេះ មិនសូវឃើញមាន យុទ្ធសាស្ត្រដោះស្រាយដោយកាត់បន្ថយចំណាយលើអាហារទៀតទេ ពីព្រោះទើបប្រមូលផលបានថ្មីៗ ហើយសេដ្ឋកិច្ចក៏រើបឡើងវិញ ។ ដូច្នេះពលករ និងក្រុមគ្រួសារនៅជនបទ អាចរក្សារបបអាហារគ្រប់គ្រាន់បាន ទោះបីអាហារនោះមានគុណភាពទាបជាងមុនក្តី ។ ការសិក្សារកឃើញ កំណើនចំណាយលើអាហារបន្តិច ក្នុងគ្រប់ក្រុមឆ្លើយសម្ភាសន៍ ដោយសារអាហារឡើងថ្លៃ មិនមែនដោយសារគុណភាពអាហាររបស់ពួកគេល្អជាងមុននោះទេ ។ អ្នកធាក់ស៊ីក្លូ ត្រូវចំណាយលើសមុន ៥០០-១០០០រៀល ក្នុងអាហារមួយពេល បើធៀបនឹងលទ្ធផលនៃការសិក្សាក្នុងជុំទី៣ ។ ប៉ុន្តែក្នុងការសិក្សាលើកនេះ គុណភាព និងបរិមាណអាហាររបស់កម្មករសំណង់គ្មានជំនាញ មិនមានផ្លាស់ប្តូរទេ ។ យុទ្ធសាស្ត្រដោះស្រាយផ្សេងៗទៀតលើកឡើងដោយកម្មករកាត់ដេរ ដើម្បីទប់ទល់នឹងការឡើងថ្លៃអាហារ រួមមាន ការហូបរួម (ទិញ ចំអិន និងហូបអាហាររួមគ្នាមួយក្រុម) និងការសុំឲ្យឪពុកម្ដាយផ្ញើអង្ករពីផ្ទះ ជាដើម ។

> *"ការហូបអាហារមានគុណភាពទាប មិនល្អសំរាប់យើងទេ ព្រោះការងារយើងត្រូវប្រើកំលាំងកាយ... ពីមុនយើងតែងហូបនំចំណីផ្សេងៗ ថែមលើអាហារហូបទៀងពេល ប៉ុន្តែឥឡូវនេះ យើងមានអារម្មណ៍អស់កំលាំងជាងមុន បន្ទាប់ពីធ្វើការរួច" (FDG ជាមួយកម្មករសំណង់មានជំនាញ)។*

### *ការទប់ទល់នឹងការប៉ះទង្គិចពីទីផ្សារពលកម្ម និងតម្រូវការការងារទាប*

កម្មករសំណង់មាន និងគ្មានជំនាញ កម្មករកាត់ដេរ អ្នកធាក់ស៊ីក្លូ អ្នករត់ទុកទុក អ្នកលក់ដូរតូចតាច កម្មករភោជនីយដ្ឋាន និងពលករចំណាកស្រុក បានប្រើយុទ្ធសាស្ត្រខុសៗគ្នា ដើម្បីទប់ទល់នឹងការប៉ះទង្គិចពី ទីផ្សារពលកម្ម និងតម្រូវការការងារទាប ។ ក្រៅពីព្រមទទួលយកប្រាក់កំរៃទាប ដោយសារមានការប្រកួតប្រជែងកាន់តែតឹងតែង កម្មករសំណង់គ្មានជំនាញជារឿយៗត្រូវទៅតាម និងរក្សាទំនាក់ទំនងល្អជាមួយមេការ ដើម្បីទទួលបានការងារធ្វើ ។ កម្មករសំណង់មានជំនាញជាច្រើនប្រាប់ថា ធ្លាប់បានទៅស្វែងរកការងារនៅការដ្ឋានផ្សេងទៀត ដែលផ្តល់កំរៃច្រើនជាងដែរ ។ កម្មករកាត់ដេរច្រើនប្តូរកន្លែងពីរោងចក្រតូចទៅរោងចក្រធំ ដើម្បីទទួលបានការងារល្អជាងមុន ។ ក្រៅពីព្រមបញ្ចុះថ្លៃឈ្នួល អ្នកធាក់ស៊ីក្លូត្រូវធ្វើដំណើរចុះឡើង ដើម្បីស្វែងរកអតិថិជន និងត្រូវធ្វើការលើសមុន ២ម៉ោង ក្នុងមួយថ្ងៃ បើធៀបនឹងឆ្នាំមុន ។ អ្នកលក់ដូរតូចតាច និងអ្នករត់ទុកទុក ត្រូវប្រកួតប្រជែងទាញយកអតិថិជន ដោយបញ្ចុះទាបបំផុតនូវថ្លៃទំនិញ និងថ្លៃសេវាដឹកអ្នកដំណើរ ។ អ្នកលក់ដូរតូចតាច បានបង្កើនចំនួនមុខផលិតផល ដើម្បីទាក់ទាញអតិថិជន ។

កម្មករតាមភោជនីយដ្ឋាននៅទីក្រុងភ្នំពេញ និយាយថា ដោយសារអតិថិជនថយចុះ ភោជនីយដ្ឋានកន្លែងខ្លួនធ្វើការ បានបង្កើតការផ្សាយទាក់ទាញ ដូចជា ផ្តល់អាហារបន្ថែមដោយឥត

គិតថ្លៃ បញ្ចុះថ្លៃអាហារ យកចិត្តទុកដាក់ខ្លាំងលើបញ្ហាអនាម័យ និង គ្រប់គ្រងតឹងរឹងលើ ពេលម៉ោងធ្វើការ ម៉ោងសម្រាកហូបបាយ និង ម៉ោងចេញពីធ្វើការរបស់បុគ្គលិកជាដើម ។ ពលករចំណាកស្រុក ហាក់ដូចគ្មានយន្តការអ្វីសម្រាប់ទប់ទល់នឹង ការថយចុះតម្រូវការជួលពលករនៅតាមកសិដ្ឋានក្នុងប្រទេសថៃទេ ។ អ្នកខ្លះនៅទំនេរក្នុងភូមិរង់ចាំការងារ អ្នកខ្លះរកបានការងារនៅតំបន់ផ្សេង ។ រឿងរ៉ាវជាក់ស្តែងមួយចំនួនបង្ហាញថា នៅភូមិអណ្តូងត្រាច ជីវភាពរបស់ប្រជាជន ពឹងពាក់តិចជាងមុនទៅលើ ធនធាននៃបឹងទន្លេសាប ។

*ការខ្ចីបុល និងការលក់ទ្រព្យសម្បត្តិ*

ការខ្ចីបុល នៅតែជាយុទ្ធសាស្រ្តដ៏សំខាន់មួយសំរាប់ដោះស្រាយការលំបាកក្នុងជីវភាព ។ ចំនួនការងារថយចុះ បានបង្ខំឲ្យពលករចំណាកស្រុកខ្ចីប្រាក់កាន់តែច្រើន ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) សំរាប់ចំណាយលើថ្លៃរស់នៅ ឬថ្លៃធ្វើចំណាកស្រុកទៅស្វែងរកការងារ ។ កម្មករសំណង់គ្មានជំនាញ និងកម្មករភោជនីយដ្ឋាន ត្រូវទៅរកខ្ចីប្រាក់ពីមិត្តភក្តិ សាច់ញាតិ អ្នកចងការប្រាក់ ឬមេការសម្រាប់ចំណាយលើថ្លៃរស់នៅ ។ អ្នកធាក់ស៊ីក្លូខ្លះ ទៅខ្ចីប្រាក់ពីអ្នកចងការប្រាក់ ឬ MFI ដោយដាក់ដីធ្លីខ្លួនជារបស់ធានា ដើម្បីយកប្រាក់ទៅទិញម៉ូតូ មកប្រកបរបរជាអ្នករត់ម៉ូតូឌុបវិញ ។ គ្រួសារជាច្រើននៅជនបទ បានជាប់បំណុលកាន់តែច្រើន ដោយសារព្រឹត្តិការណ៍ក្នុងគ្រួសារ ដូចជា ការរៀបការកូនចៅជាដើម ។ ការទិញធាតុចូលកសិកម្មដោយប្រើ ឥណទានមានការប្រាក់ខ្ពស់ ធ្វើឲ្យកសិករត្រូវសងប្រាក់យ៉ាងច្រើន ទៅឲ្យពាណិជ្ជករជាម្ចាស់បំណុល ។ ទិន្នផលស្រូវទាបនៅតាមភូមិដែលរងការខូចខាតផលដំណាំដោយសារ ការបំផ្លិចបំផ្លាញដោយសត្វចង្រៃ និងភ្លៀងធ្លាក់ខ្លាំងជាដើម ក៏នឹងបង្កកំណើនបំណុលស្ទើរជៀសមិនផុត ចំពោះគ្រួសារនៅតាមភូមិទាំងនោះ នៅឆ្នាំខាងមុខ ។ គ្រួសារនានាដែលមិនអាចសងបំណុលទៅឲ្យ MFI ឬ ធនាគារបាន ត្រូវទៅរកខ្ចីប្រាក់ពីប្រភពដទៃទៀត ដូចជា អ្នកចងការប្រាក់ក្នុងភូមិជាដើម ទោះបីមានការប្រាក់ខ្ពស់ក៏ដោយ ដើម្បីយកទៅសងបំណុល ព្រោះខ្លាចបាត់បង់ផ្ទះ ឬដីដែលខ្លួនដាក់ធានា ។ ការសងកំចីដោយប្រើកំចីមួយទៀត វាបង្កការលំបាកមួយជាន់ថែមទៀត ។

ករណីលក់ទ្រព្យសម្បត្តិ ឃើញមានរាយការណ៍តិចតួចបំផុតនៅក្នុង FGDs ដែលអាចមកពីមូលហេតុពីរយ៉ាងគឺ៖ ទីមួយ គ្រួសារប្រហែលគ្មានទ្រព្យអ្វីសំរាប់លក់ទៀត ដូចជានៅភូមិដូនវង្ស ក្នុងស្រុកកណ្តាលស្ទឹងខេត្តកណ្តាលនិងភូមិអណ្តូងត្រាចជាដើម។ ទីពីរ កំណើនការងារឡើងវិញក្នុងវិស័យកាត់ដេរ អាចជួយដល់គ្រួសារនៅតាមជនបទ តាមរយៈប្រាក់ផ្ញើមកផ្ទះ និងប្រាក់ចំណូលពីការងារក្រៅកសិដ្ឋាន ដែលពួកគេរកបានក្នុងអំឡុងពេលធ្វើការសិក្សានេះ ។ ការលក់សត្វចិញ្ចឹម នៅពេលត្រូវការប្រាក់ ជារបៀបអនុវត្តទូទៅមួយ បើតាមសំដីរបស់អ្នកភូមិជាច្រើន ។

**ជំនួយសង្គម និងទំនាក់ទំនងសង្គម**

ដូចការសិក្សានៅជុំមុនៗដែរ យើងមិនឃើញមានជំនួយសង្គមជាផ្លូវការអ្វីថ្មីពីរដ្ឋាភិបាលឬទីភ្នាក់ងារអភិវឌ្ឍន៍សម្រាប់ជួយប្រជាជនទប់ទល់នឹងវិបត្តិ ក្នុងអំឡុងពេលសិក្សានេះទេ (ខែធ្នូ ២០០៩-កុម្ភៈ ២០១០) ។ សេវាសង្គមដែលមានស្រាប់ រួមមាន ការចាក់ថ្នាំបង្ការ និងការបែងចែកអាហារូបត្ថម្ភសំរាប់កុមារ និងស្រ្តីមានគភ៌ ។ នៅភូមិត្រពាំងប្រីយ៍ អ្នកស្រុកទទួលបានអត្ថប្រយោជន៍ពីកម្មវិធីអភិវឌ្ឍន៍ជនបទគ្រប់ជ្រុងជ្រោយមួយ របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ដែលមានដូចជា ការផ្តល់សត្វចិញ្ចឹម និងអនាម័យក្នុងសហគមន៍ជាដើម ។ សំរាប់កម្មករកាត់ដេរ សមាជិកភាពក្នុងសហជីពកម្មករ បានផ្តល់ជំនួយទ្រទ្រង់ឲ្យពួកគេក្នុងការចរចាជាមួយម្ចាស់រោងចក្រ ។ ចំណុចនេះឆ្លុះបញ្ចាំងពីកង្វះខាតកម្មវិធីការពារសង្គម សំរាប់ជនក្រីក្រ និងងាយរងគ្រោះ ប៉ុន្តែមានបណ្តាញសន្តិសុខសង្គមក្រៅផ្លូវការផ្សេងៗ បានមកជំនួស ឬជួយបំពេញដល់បណ្តាញជាផ្លូវការ ។ អ្នកផ្តល់ព័ត៌មានគ្រប់គ្នាក្នុង FGDs ប្រាប់ថា ការជួយគ្នាទៅវិញទៅមក ចំណងសាច់ញាតិ និងសាមគ្គីភាពក្នុងក្រុម គឺជាបណ្តាញសន្តិសុខសង្គមដែលអាចពឹងពាក់បានក្នុងគ្រាលំបាក ឬនៅពេលមានតម្រូវការជំនួយបន្ទាន់ ។

## សេចក្តីសន្និដ្ឋាន

ការវាយតម្លៃជុំទីបួននេះ បានបញ្ជាក់នូវកំណើនដ៏ទៀងទាត់នៃវិស័យកាត់ដេរនិងទេសចរណ៍ព្រមទាំងការរើបនៃវិស័យសំណង់។ ការស្ទុះឡើងវិញនៃវិស័យដែលរងការប៉ះទង្គិចខ្លាំងទាំងនេះ បានជួយកែលំអខ្លះៗ ដល់ជីវភាពរស់នៅរបស់កម្មករងាយរងគ្រោះជាច្រើន និងក្រុមគ្រួសាររបស់ពួកគេ ។ ទោះជាវិបត្តិសេដ្ឋកិច្ចបានធូរស្រាលមកវិញក្តី ប៉ុន្តែផលប៉ះពាល់អវិជ្ជមានរបស់វា នៅតែបន្តកើតមានលើ កម្មករសំណង់គ្មានជំនាញ អ្នកធាក់ស៊ីក្លូ កម្មករភោជនីយដ្ឋាន និងពលករចំណាកស្រុក ក្នុងទម្រង់ជាការថយចំនួនប្រាក់ចំណូល និងការងារអាចរកបាន ។ គេមិនឃើញមានបំលាស់ប្តូរអ្វីគួរកត់សំគាល់ ទាក់ទងនឹងចំណាយលើអាហារ និងទំនិញមិនមែនអាហារ របស់ក្រុមពលករទាំងនេះទេ ។

យន្តការផ្សេងៗសម្រាប់ទប់ទល់នឹងវិបត្តិ រួមមាន៖ (១) ការកាត់បន្ថយចំណាយប្រើប្រាស់មិនមែនអាហារ និងគុណភាពអាហារ (២) ការបន្តស្វែងរកការងារ ការធ្វើការខ្លាំងជាងមុន និងការកែតម្រូវយុទ្ធសាស្តធ្វើអាជីវកម្ម (៣) ការខ្ចីបុល និងលក់ទ្រព្យសម្បត្តិ ។ ប្រជាជនបន្តទទួលបានការទ្រទ្រង់ពីបណ្តាញសន្តិសុខសង្គមក្រៅផ្លូវការ ក្នុងគ្រាជួបការលំបាកខ្លាំង ។ សេវាសង្គមតិចតួចដែលអាចរកបាន មិនអាចឆ្លើយតបគ្រប់គ្រាន់ទៅនឹងវិបត្តិសេដ្ឋកិច្ចទេ ។ ចំណុចនេះបង្ហាញថា គួរពង្រីកវិសាលភាពនៃប្រព័ន្ធសន្តិសុខសង្គមផ្លូវការ ។ ការរើបឃើតនៃវិស័យជំរុញកំណើននានា ធ្វើឲ្យប្រជាជនដែលពឹងពាក់លើវិស័យទាំងនោះជួបការលំបាក ។ ដូច្នេះត្រូវធ្វើពិពិធកម្មវិស័យជំរុញកំណើន ដើម្បីធានាឲ្យកំណើនកាន់តែមានចីរភាព ។ ការធានាឲ្យអត្ថប្រយោជន៍នៃកំណើនបានទៅដល់ប្រជាជនក្រីក្រមួយភាគធំ ដែលច្រើនរស់នៅទីជនបទ និងការជំរុញវិស័យអភិវឌ្ឍន៍តិចជាងគេ ដូចជាកសិកម្មជាដើម គួរយកមកគិតគូរខ្លាំងជាងគេ ៕

## ឯកសារយោង

សូមមើលក្នុងឯកសារជាភាសាអង់គ្លេស ។